សម្រង់គតិយុត្ត

(ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤)

ស្តីពី

# ទណ្ឌកម្មវិន័យ និងការចោទប្រកាន់តាមផ្លូវតុលាការ ចំពោះ ចៅក្រម-ព្រះរាជអាជ្ញា



រៀបរៀងដោយ ៖ នីតិកោសល

ខែសីហា ឆ្នាំ២០២០

# ទណ្ឌកម្មវិន័យ

**មាត្រា ៥៤._**

កំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ ស្មារតស្មុំ និងសេចក្តីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា នាំឲ្យមានទណ្ឌកម្មខាងវិន័យតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ប៉ុន្តែ ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ចៅក្រម និងព្រះរាជអាជ្ញាក្នុងការអនុវត្តច្បាប់មិនត្រូវចាត់ទុកថាជាកំហុសខាងវិន័យឡើយ។

ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត។

ចៅក្រមអាចត្រូវបានផ្អាកពីមុខងារជាបណ្តោះអាសន្ន ដោយប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងករណីដែលចៅក្រមនោះ កំពុងជាប់នៅក្នុងនីតិវិធីវិន័យរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**មាត្រា ៥៥._**

ទណ្ឌកម្មខាងវិន័យមាន ២ (ពីរ) ថ្នាក់គឺ ៖

១-ទណ្ឌកម្មថ្នាក់ទី ១ (មួយ)

ក- ការស្តីបន្ទោសដោយផ្ទាល់មាត់

ខ- ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ- ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬ ឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឲ្យលើសពី ២ (ពីរ) ឆ្នាំទេ ឬ លុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬ ឋានន្តរស័ក្តិវិញក្នុងករណីដែលមានចុះឈ្មោះរួចហើយ។

២-ទណ្ឌកម្មថ្នាក់ទី ២ (ពីរ)

ក- ការផ្លាស់ដោយបង្ខំ អាចតម្រូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម

ខ- ការព្យួរពីការងារមិនឲ្យមានបៀវត្ស ក្នុងរយៈពេលមិនឲ្យលើសពី ១ (មួយ) ឆ្នាំ

គ- ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ

ឃ- ការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ

ង- ការបញ្ឈប់ពីមុខងារដោយបង្ខំ

ច- ការបណ្តេញចេញពីក្របខណ្ឌ។

ទណ្ឌកម្មថ្នាក់ទី ២ (ពីរ) ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យបន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**មាត្រា ៥៦._**

ក្នុងករណីមានការបញ្ឈប់ពីមុខងារដោយបង្ខំ ឬ ការបណ្តេញចេញពីក្របខណ្ឌដោយអនុលោមតាមបញ្ញត្តិនៃច្បាប់នេះ សាមីខ្លួនមានសិទ្ធិទទួលយកប្រាក់ទាំងអស់ដែលបេឡាសោធននិវត្តន៍បានកាត់លើប្រាក់បៀវត្សរបស់ខ្លួនរួចមកហើយ តាមច្បាប់ ឬបទបញ្ញានៃបេឡាសោធននិវត្តន៍។

# ការចោទប្រកាន់តាមផ្លូវតុលាការ

**មាត្រា ៥៧._**

ចៅក្រមដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ អាចត្រូវទទួលការចោទប្រកាន់តាមផ្លូវតុលាការ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចផ្ទេរសមត្ថកិច្ច

ទៅសាលាដំបូងផ្សេង ក្រៅពីសាលាដំបូងដែលចៅក្រមនោះបំពេញមុខងារ។

ក្នុងករណីដែលចៅក្រមណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នោះទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងរយៈពេល ៧២ ម៉ោង យ៉ាងយូរ។

បើមានការចាប់ ឬ ឃាត់ខ្លួនចៅក្រមណាម្នាក់ អាជ្ញាធរដែលមានសមត្ថកិច្ច ត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អំពីការចាប់ ឬ ការឃាត់ខ្លួននោះ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវជូនព័ត៌មានខាងលើនេះជាបន្ទាន់ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**មាត្រា ៥៨._**

ចៅក្រមដែលទទួលការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវផ្អាកដោយស្វ័យប្រវត្តិមិនឲ្យបំពេញមុខងារ

ទៅសាលាដំបូងផ្សេង ក្រៅពីសាលាដំបូងដែលចៅក្រមនោះបំពេញមុខងារ។

ក្នុងករណីដែលចៅក្រមណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នោះទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងរយៈពេល ៧២ ម៉ោង យ៉ាងយូរ។

បើមានការចាប់ ឬ ឃាត់ខ្លួនចៅក្រមណាម្នាក់ អាជ្ញាធរដែលមានសមត្ថកិច្ច ត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អំពីការចាប់ ឬ ការឃាត់ខ្លួននោះ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវជូនព័ត៌មានខាងលើនេះជាបន្ទាន់ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

## មាត្រា ៥៨._

ចៅក្រមដែលទទួលការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវផ្អាកដោយស្វ័យប្រវត្តិមិនឲ្យបំពេញមុខងារ

ជាបណ្តោះអាសន្ន តាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាប់ពីថ្ងៃដែលសាលក្រមតុលាការសម្រេចថាមានទោស ទោះបីមានបណ្តឹងឧទ្ធរណ៍ពីសាលក្រមនេះក៏ដោយ។

**មាត្រា ៥៩._**

ក្នុងករណីដែលចៅក្រមជាប់ចោទតាមផ្លូវតុលាការទទួលបានការលើកលែងចោទប្រកាន់ ឬត្រូវបានសម្រេចឲ្យរួចផុតពីបទចោទប្រកាន់ជាស្ថាពរ ចៅក្រមនោះត្រូវបានទទួលឲ្យចូលធ្វើការវិញភ្លាមដោយគិតពីអតីតភាពថ្នាក់ និងឋានន្តរស័ក្តិ សោធននិវត្តន៍ និងទទួលប្រាក់បៀវត្សដែលត្រូវផ្អាកជាបណ្តោះអាសន្នពីមុនមកវិញទាំងអស់។

បញ្ញត្តិនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលចៅក្រមនោះពុំត្រូវបានលុបឈ្មោះចេញពីក្របខណ្ឌចៅក្រមដោយអនុវត្តតាមបញ្ញត្តិនៃមាត្រា ៦១ នៃច្បាប់នេះ។

## មាត្រា ៦០._

ទោះបីមានសេចក្ដីសម្រេចពីតុលាការ លើកលែងចោទប្រកាន់ ឬសម្រេចឲ្យរួចផុតពីបទចោទប្រកាន់ ឬផ្ដន្ទាទោសក្ដី បើសាមីខ្លួនប្រព្រឹត្តខុស នឹងក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា សាមីខ្លួនអាចដាក់ឲ្យចោទប្រកាន់ជាប់វិន័យថែមទៀត ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

## មាត្រា ៦១._

ការផ្ដន្ទាទោសជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិមប្រព្រឹត្តដោយចេតនា ដោយគ្មានការព្យួរទោសបណ្ដាលឲ្យមានការលុបឈ្មោះចេញពីក្របខណ្ឌចៅក្រម គិតពីថ្ងៃសាលក្រម ឬសាលដីកាចូលជាស្ថាពរ។

**បញ្ជាក់** ៖

- ❖ មាត្រា ៥៤ ដល់មាត្រា ៥៦ នៃច្បាប់នេះ គឺបញ្ញត្តពាក់ព័ន្ធនឹងទណ្ឌកម្មវិន័យ ដោយអនុវត្តដូចគ្នាចំពោះចៅក្រម និងព្រះរាជអាជ្ញា (មាត្រា ៩៩ នៃច្បាប់នេះ)។
- ❖ មាត្រា ៥៧ ដល់មាត្រា ៦១ នៃច្បាប់នេះ គឺបញ្ញត្តពាក់ព័ន្ធនឹងការចោទប្រកាន់តាមផ្លូវតុលាការ ដោយអនុវត្តដូចគ្នាចំពោះចៅក្រម និងព្រះរាជអាជ្ញា (មាត្រា ១០០ នៃច្បាប់នេះ) ។